# សេចក្តីជូនដំណឹងនៃច្បាប់ការពារជនពិការអាមេរិកាំង – ADA

# ច្បាប់ប្រតិបត្តិ និង នីតិវិធី

សេចក្តីជូនដំណឹងនៃច្បាប់ការពារជនពិការអាមេរិកាំង

យោងទៅតាមល័ក្ខខណ្ឌនៃសេចក្តីតម្រូវនៅក្នុងចំណងជើងទី II នៃច្បាប់ការពារជនពិការអាមេរិកាំង ("ADA") នៃឆ្នាំ 1990, ក្រសួងសង្គមកិច្ចសាធារណៈនឹងមិនរើសអើងប្រឆាំងនឹងបុគ្គលដែលមានសិទ្ធិទទួលជំនួយដែលពិការ ដោយផ្អែកលើមូលដ្ឋាននៃភាពពិការ នៅក្នុងការផ្តល់សេវា, កម្មវិធី, ឬ សកម្មភាពផ្សេងៗឡើយ។

**ការទំនាក់ទំនងដែលមានប្រសិទ្ធិភាព:** ក្រសួងសង្គមកិច្ចសាធារណៈ ដោយអាស្រ័យទៅលើសំណើ នឹង, ផ្តល់នូវជំនួយ និង សេវាកម្មផ្សេងៗដែលនាំទៅដល់ការទំនាក់ទំនងដែលមានប្រសិទ្ធិភាព សំរាប់មនុស្សដែលមានសិទ្ធិទទួលជំនួយដែលពិការ ដើម្បីឱ្យគេអាចចូលរួមបានស្មើភាពគ្នានៅក្នុងកម្មវិធីរបស់ក្រសួងសង្គមកិច្ចសាធារណៈ, សេវាកម្មនានា, និង សកម្មភាពទាំងឡាយ ដែលមានរួមទាំង ទទួលបាននូវអ្នកបកប្រែភាសាសញ្ញាដែលមានអាជ្ញាប័ណ្ណ, ទទួលបានឯកសារជាអក្សរពុម្ពទំហំធំ, ព្រមទាំង វិធីដទៃទៀតនៅក្នុងការផ្តល់ព័ត៌មាន និងការទំនាក់ទំនងដែលមនុស្សដែលមានបញ្ហាក្នុងការនិយាយ, ការស្តាប់, ឬ ការមើល អាចចូលទៅឬប្រើប្រាស់បាន។

**ការកែសម្រួលលើច្បាប់ប្រតិបត្តិនិងនីតិវិធី:** ក្រសួងសង្គមកិច្ចសាធារណៈនឹងធ្វើការកែសម្រួលទាំងអស់ដែលសមរម្យទៅលើច្បាប់ប្រតិបត្តិនិងកម្មវិធីផ្សេងៗ ដើម្បីធ្វើឱ្យបានប្រាកដថាមនុស្សដែលពិការ មានឱកាសស្មើភាពគ្នាក្នុងការទទួលបាននូវការរីករាយជាមួយនឹងកម្មវិធី, សេវាកម្ម, ហើយនិង សកម្មភាពផ្សេងៗរបស់ក្រសួង។ ឧទាហរណ៍, ជនដែលមានសត្វជួយដឹកនាំផ្លូវគឺត្រូវបានស្វាគមន៍ដោយការិយាល័យក្រសួងសង្គមកិច្ចសាធារណៈ, ទោះបីជា កន្លែងដែលជាធម្មតា សត្វចិញ្ចឹមត្រូវបានហាមឃាត់ ក៏ដោយ។

អ្នកណាម្នាក់ដែលត្រូវការជំនួយបន្ទាប់បន្សំ, ឬកិច្ចការបំរើសំរាប់ការទំនាក់ទំនងដែលមានប្រសិទ្ធិភាព, ឬការកែសម្រួលនៃច្បាប់ប្រតិបត្តិឬនីតិវិធីដើម្បីចូលរួម នៅក្នុងកម្មវិធី, សេវាកម្ម, សកម្មភាពនៃក្រសួងសង្គមកិច្ចសាធារណៈនោះ, គួរតែទំនាក់ទំនងទៅលេខទូរស័ព្ទពិសេសផ្នែក ADA តាមលេខ (844) 586-5550 ឱ្យបានយ៉ាងឆាប់ជាទីបំផុត, ប៉ុន្តែ កុំឱ្យលើសពី 48 ម៉ោង មុនពេលព្រឹត្តិការណ៍ដែលបានគ្រោងទុក។

ADA មិនតម្រូវឱ្យក្រសួងសង្គមកិច្ចសាធារណៈចាត់វិធានការណ៍ ដែលនឹងជាគ្រឹះនៃការកែប្រែលក្ខណៈនៃកម្មវិធី ឬសេវាកម្មរបស់ក្រសួង, ឬ ដាក់កំរិតទៅលើបន្ទុកនៃហិរញ្ញវត្ថុ ឬបន្ទុកនៃរដ្ឋបាលដែលហួសហេតុណាមួយឡើយ។

ពាក្យបណ្តឹងដែលថាកម្មវិធី, សេវាកម្ម, ឬ សកម្មភាពនៃក្រសួងសង្គមកិច្ចសាធារណៈ មិនអាចចូលទៅឬប្រើប្រាស់បានសំរាប់មនុស្សដែលពិការ គួរតែបញ្ជូនដោយផ្ទាល់ទៅលេខទូរស័ព្ទពិសេសផ្នែក ADA លេខ (844) 586-5550។

ក្រសួងសង្គមកិច្ចសាធារណៈនឹងមិនដាក់ថ្លៃបន្ថែមទៅលើមនុស្សដែលពិការជាពិសេស ឬក្រុមនៃមនុស្សដែលពិការណាមួយ ដើម្បីរ៉ាប់រងថ្លៃផ្តល់ជំនួយបន្ទាប់បន្សំ/សេវាកម្មផ្សេងៗ ឬការកែសម្រួលដែលសមរម្យលើច្បាប់ប្រតិបត្តិ, ដូចជា ការទៅយករបស់ឬវត្ថុផ្សេងៗមកពីកន្លែងនានា ដែលបើកសំរាប់សាធារណជនប្រើប្រាស់បាន ប៉ុន្តែ មនុស្សដែលប្រើកៅអីមានកង់មិនអាចចូលទៅឬប្រើប្រាស់បាន។

# នីតិវិធីបណ្តឹង

នីតិវិធីបណ្តឹងគឺបានបង្កើតឡើងដើម្បីឱ្យបានសមស្របតាមល័ក្ខខណ្ឌនៃសេចក្តីសម្រេចនៅក្នុងចំណងជើងទី II នៃច្បាប់ការពារជនពិការអាមេរិកាំង ("ADA") នៃឆ្នាំ 1990។ ពាក្យបណ្តឹងនេះប្រហែលជាអាចប្រើដោយអ្នកណាម្នាក់ដែលមានបំណងចង់ដាក់ពាក្យប្តឹងអះអាងថាមានការរើសអើង  ផ្អែកទៅលើមូលដ្ឋាននៃភាពពិការ នៅក្នុងការផ្តល់សេវា, សកម្មភាព, កម្មវិធី, ឬ ប្រយោជន៍ជំនួយ ដោយក្រសួងសង្គមកិច្ចសាធារណៈ។ ច្បាប់ប្រតិបត្តិនៃនាយកដ្ឋានចាត់តាំងរបស់ខោនធី គ្រប់គ្រងពាក្យបណ្តឹងអំពីការរើសអើងខាងពិការភាពដែលទាក់ទងនឹងការងារ។

ពាក្យបណ្តឹង គួរតែមានព័ត៌មានអំពីការរើសអើងដែលបានចោទប្រកាន់ ដូចជា ឈ្មោះ, អាសយដ្ឋាន, លេខទូរស័ព្ទរបស់អ្នកដាក់ពាក្យប្តឹង និង ទីកន្លែង, ខែថ្ងៃឆ្នាំ, និង សេចក្តីរៀបរាប់អំពីបញ្ហានោះ។ មធ្យោបាយផ្សេងទៀតនៃការដាក់ពាក្យបណ្តឹង, ដូចជា ការធ្វើបទសម្ភាស៍ផ្ទាល់ ឬថតកាសែតទុកនូវពាក្យបណ្តឹងតវ៉ា, នឹងត្រូវបានធ្វើឱ្យមានប្រើប្រាស់បានសំរាប់មនុស្សដែលពិការ តាមការស្នើសុំ។

ពាក្យបណ្តឹងគួរតែផ្ញើបញ្ជូនទៅភាគីប្តឹងតវ៉ា និង/ឬ អ្នកតំណាងរបស់គាត់/នាង ឱ្យបានយ៉ាងឆាប់ជាទីបំផុត ប៉ុន្តែកុំឱ្យលើសពី 180 ថ្ងៃប្រតិទិន បន្ទាប់ពីការរំលោភដែលបានចោទប្រកាន់:

Civil Rights Section
12860 Crossroads Parkway South
City of Industry, CA 91746

ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទាំងអស់ដែលបានទទួលដោយអង្គភាពផ្នែកសិទ្ធិមនុស្ស, ដែលដាក់ប្តឹងទៅការិយាល័យនាយកគ្រប់គ្រងផ្នែកសិទ្ធិមនុស្សសំរាប់ជនពិការ, ហើយ ការឆ្លើយតបពីការិយាល័យទាំងពីរនេះនឹងត្រូវបានរក្សាទុកដោយក្រសួងសង្គមកិច្ចសាធារណៈក្នុងអំឡុងពេលយ៉ាងតិចបំផុតបីឆ្នាំ។